# កម្លាំង យួន នៅ ស្រុកខ្មែរ

## La force vietnamienne au Cambodge

**សរសេរ ដោយ ឧប សៅ សង្ហា**

**១២ ធ្នូ ឆ្នាំ ២០១៤**



## មាតិការឿង

**វៀតណាម យល់ឃើញ ជាតិសាសន៍ ខ្មែរ បែបណា ?**

**ជនយួន យល់ឃើញ ជនខ្មែរ បែបណា ?**

**សង្ខេប អំពី ធាតុ ឥណ្ឌូចិន**

- អារ្យធម៌ចិន
- អារ្យធម៌ ឥណ្ឌា
- វប្បធម៌ អឺរ៉ុប
- ការទង្គិចគ្នា នៃ ភាពទំនើប នៅ ឥណ្ឌូចិន
  . នៅស្រុកខ្មែរ
  . នៅស្រុកយួន

**គណបក្ស ប្រឆាំង**

**វរជន ថ្មី និង បេសកកម្ម យួនកម្ពុជា**

**សេចក្តី សន្និដ្ឋាន**

## វៀតណាម យល់ឃើញ ជាតិសាសន៍ ខ្មែរ បែបណា ?

ចំពោះ វៀតណាម, គេ ទុក ខ្មែរ ជា ជាតិពន្ធ មួយ ក្នុងចំណោម ជាតិពន្ធ ឯទៀតៗ មាន នៅ ក្នុង ស្រុកខ្មែរ ដូច ជា ចិន យួន ចាម ខ្មែរលើ ។ល។ ហេតុនេះ ឯង កាល វៀតណាម កាន់កាប់ ស្រុកខ្មែរ ក្នុងរយះពេល មួយ ទស្សវត្សរ៍ (១៩៧៩-១៩៨៩) អាជ្ញា អាណានិគម វៀតណាម នៅស្រុក ខ្មែរ គេ យក ពាក្យ «កម្ពុជា» មកប្រើ ជា ផ្លូវការ ក្នុង ប័ត្រអត្តសញ្ញាណ ប្រជាជន រស់នៅក្នុង ស្រុកខ្មែរ ដើម្បី ចែកឲដាច់គ្នា រវាង អត្តសញ្ញាណ ប្រជាជន និង ជាតិពន្ធ។ នៅក្នុង **បញ្ញាតិ**[1] បែបនេះ វៀតណាម មាន គោលបំណង យក «**សិទ្ធិធរណី**[2]» មកធ្វើ ជា គោលច្បាប់ សញ្ញាតិ ខ្មែរ ដើម្បី ឲ យួន កើត នៅក្នុង ស្រុកខ្មែរ ងាយស្រួល នឹងទទួលបាន អត្តសញ្ញាណ ជា ប្រជាជន ប្រទេស កម្ពុជា។  ខ្មែរ អ្នកតែង ច្បាប់ បានយក ការប្រតិបត្តិ បែបនេះ មកធ្វើ ជា ច្បាប់ សញ្ញាតិ ខ្មែរ ដែលនាំ ឲ ជនជាតិ យួន រាប់ លាន នាក់  រស់ នៅក្នុង ស្រុកខ្មែរទទួលបាន អត្តសញ្ញាណ  ជា ប្រជាជន «កម្ពុជា» ងាយស្រួល បំផុត ក្នុង ឆ្នាំ ១៩៩៦[3]។ ជនកម្ពុជា ដែលមាន ដើមកំណើត ជា ជាតិសាសន៍ យួន នេះឯង ជា អ្នកបោះឆ្នោត ទៀងទាត់ ឲ គណបក្សប្រជាជន ហើយចំនួន ក៏កាន់តែ ជឿនឡើង ពី អាណត្តិ មួយ ទៅ អាណត្តិ មួយទៀត ដែល អាច រក្សា អត្ថិភាព គណបក្សប្រជាជន ជានិច្ច នៅក្នុង ជីវិតនយោបាយខ្មែរ។ ស្ថានភាព ឥតអាច វិលត្រឡប់ថយក្រោយ វិញបាន នេះហើយ ដែល ជា ការពិត ដែល ខ្មែរយើង មិនអាច ប្រកែកបាន នោះឡើយ។ បច្ចុប្បន្ន នេះ ជនជាតិ កម្ពុជា[4] មានចំនួន ស្ទើរ តែស្មើនឹង ជនជាតិខ្មែរ ទៅហើយ គឺ ប្រមាណ ពី ៥ លាន ទៅ ៦ លាន នាក់ មិនមែនដូច លោកសម-រង្សី ប្រកាស ថា យួន មាន ៤ សែន នាក់ ហើយ ពាក់ កណ្តាល មាន សញ្ញាតិ ជា ខ្មែរ រួចហើយ នោះឡើយ។ ការពិត នេះហើយ ដែល តម្រូវ ឲ ខ្មែរ រក ដំណោះស្រាយ សក្តិសិទ្ធ ណាមួយនៅ ចំពោះមុខ ការគំរាម កំហែង នេះ។ ពុំនោះ សោធ ជាតិសាសន៍ ខ្មែរ នឹងក្លាយ ជា ជនជាតិ ភាគតិច នៅក្នុងប្រទេស របស់ខ្លួន ដែល ខ្លួន ជាម្ចាស់ ស្រុក។

តាម វិជ្ជាឋានជាតិ ស្ថិតិ ចុះផ្សាយ និវេទន៍ នៃ វត្ថុធាតុ ជាតិ សំខាន់ៗ នា ឆ្នាំ ១៩៦៩ ក្នុងនោះ តាម ការស្រង់ចំនួនប្រជាជន នាឆ្នាំ១៩៦៨ មាន ចំនួន ៦.៥00.000 នាក់ មាន អាណិកជន ចិន ប្រមាណ ៥00.000 នាក់ និង យួន ប្រមាណ ៤៥0.000, ដូច្នេះ អត្រា អាណិកជន យួន គឺ ៦,៩% ដោយ ប្រៀបធៀប ទៅនឹង ប្រជាជនខ្មែរ។ គួរ ដឹងដែរ ថា មាន ខ្មែរ **អ្នកនិយម ភូមិសាស្ត្រវិជ្ជា**[5] ខ្លះគាត់ ធ្វើ ស្ថិតិ លេខ គ្រោងទៅមុខ ដ៏ចម្លែង ថា បើ ប្រជាជន ខ្មែរ សព្វថ្ងៃ មាន ប្រមាណ១៥លាននាក់ ដូច្នេះ អាណិកជន យួន ត្រូវមាន ១.0៣៥.000 នាក់ គឺ យក លេខ ១៥ លាន នាក់ គុណ នឹង អត្រា ៦,៩% តែ ម្តង។ របៀប គណតិ បែបនេះ ឯងដែល ប្រតិបត្តិ ឡើង បំរើប្រយោជន៍ យួន ដោយ ឥតដឹង ខ្លួនផង ហើយ ជា របៀប គណតិ ដ៍

[1] បញ្ញាតិ=គំនិតជាទូទៅ (concept)៕
[2] សិទ្ធិធរណី= Droit du sol។
[3] ច្បាប់ សញ្ញាតិ ខ្មែរ ត្រូវបានប្រកាសជាផ្លូវការ នៅថ្ងៃ ទី៩ តុលា ឆ្នាំ ១៩៩៦។
[4] ជនជាតិកម្ពុជា= យួនដែលមានសញ្ញាតិជាខ្មែរ គេទុកខ្លួនគេ ជា ជនកម្ពុជា។
[5] អ្នកនិយម ភូមិសាស្ត្រវិជ្ជា= Géographe amateur។

ចម្លែក មួយ ដែលយើង ឥតបាន គិតស្មាន ថា មាន អ្នកគិត ដូច្នេះ។ មួយវិញទៀត មានខ្មែរ រស់នៅ បរទេស គាំទ្រ គណបក្ស សង្គ្រោះជាតិ នាំគ្នា ជេរ យួន ស្រួលណាស់ ពី បរទេស តែ ភ្លេច គិត ថា នៅឯ ក្នុង ប្រទេសវិញ មេដឹកនាំ ខ្លួន លែងហ៊ាន និយាយ រិះគន់ នយោបាយ អាណានិគមយួន ព្រោះ ពួក គាត់ រស់ បានដោយសារ យួន គេ ជា អ្នកផានា សេចក្តីសុខ ឲ ពួក គាត់ បើ ពួក គាត់ សុខចិត្ត រស់នៅ ក្រោម អំណាចហ៊ុន-សែន ហើយ ចេះអត់ធ្មត់នូវ ការ ជេរប្រមាថ របស់ បុគ្គល ខ្លាំងកម្លាំងសាច់ដុំ នេះ។ តែគួរឲ ចម្លែក ពួកទាំងនេះ បើឮ គេ និយាយ ថា មានយួន ច្រើន នៅស្រុកខ្មែរស្រាប់ តែ ខឹង ដូចជា គេប្រមាថ មើលងាយ ខ្លួនឯង ផ្ទាល់ ឆ្លើយដោយ កំហល់ ថាខ្លួន ក៏ធ្លាប់ទៅ ស្រុកខ្មែរ វាគ្មានឃើញដូច អ្នកឯង និយាយ នោះ ឡើយ តែ គាត់ភ្លេច ថា បើគាត់ គ្រាន់តែមើល នឹងភ្នែក តែ មិនយក សតិ មក គិត គឺច្បាស់ ជាគាត់ មានភ្នែក ដូច លោក ហ៊ុន-សែន នោះឯង។ ម្យ៉ាងមយួទៀត នៅក្នុងចំណុចនេះ គួរ ឲយើង ចង់ សើច ដែរ ព្រោះ ពួកគាត់ មានបំណង យក រឿងរ៉ាវ ប្រឆាំងនឹង យួន ជា **ឯកាធភាព**[6] របស់ គាត់ តែ ការប្រឆាំង របស់ ពួកគាត់ គ្មាន ខួរ ព្រោះ ដូចបាន ជំរាប ខាងលើ រួច មកហើយ ថា ខួរក្បាល លោក សម-រង្ស៊ី និង កែម-សុខា វាក្លាយ ជា ខួរក្បាល យួន រួចស្រេចទៅ ហើយ។ ដូចយ៉ាង លោក សម-រង្ស៊ី គាត់ សុខចិត្ត សុខកាយ ទទួល ងារ ដែល យួន ចែកឲ គឺ តំណាងរាស្ត្រ មិនចាំបាញ់ បោះឆ្នោត ហើយ ថ្មីៗ ទទួល ងារ ជា «នាយករដ្ឋមន្ត្រីស្រមោល» ដែល ហ៊ុន-សែន សុំ អនុញ្ញាត ពីយួន ដើម្បី បំពាក់ ឲខ្លួន។ តើ ខ្មែរយើង អាច ចាត់ទុក បុគ្គល សម-រង្ស៊ី ជា មនុស្ស ប្រភេទ ណាដែរ ?

ល្ងើយ គំនិត អាស្រូវ បែប នេះ ទុក ជា កម្មខ្មែរ ទៅចុះព្រោះ បើយកវា មកគិតក៏វា គ្មាន ប្រយោជន៍ អ្វិ ដល់ជាតិ នោះដែរ៖ មនុស្សបើគ្មាន ខួរ ទោះ បី មាន ភ្នែក ក៏ ដូច ជា មនុស្ស មាន ចក្ខុងងឹត នឹងចង់ មើលអ្វី ក៏អាច មើលមិនបាន ទួទៅ ដែរ គឺ ដូច ជា មនុស្ស ខ្វាក់ នោះឯង។ តែ បើ អ្នកមានចំណេះវិជ្ជា តែ មើលមិនបាន ទួទៅ ទោះបី មាន វិជ្ជាខ្ពង់ខ្ពស់ យ៉ាងណា ក៏ដោយ គឺ គេ ទុក ជា មនុស្ស, ឥតមាយាទ ឥតក្តី **ហិរិឱត្តប្បៈ**[7] គ្មានខ្មាស សព្វមនុស្សលោក, ប្រព្រឹត្ត តាម គតិ មនុស្សពាល ដូចមាន នៅក្នុង គតិលោក របស់ ឧកញ៉ា**សុត្តន្តប្រីជាឥន្ទ** មានចែង មនុស្ស ជា ពីរប្រភេទ៖ សុភាជន និង ទុច្ចរិតជន ; មួយ ជា អ្នកនាំមក នូវ សេចក្តីសុខ ដល់ ជនដទៃ និង អាត្មាឯង ផង មួយទៀត ជា មនុស្ស ចង្រៃ នាំមក តែ សេចក្តី ទុក្ខវេទនា សេចក្តីវិនាស គ្រប់ប្រការ ដល់ មនុស្សជាតិ និង អាត្មាឯង វង្វេង នៅក្នុង គតិពាល បើជា អ្នក ដឹកនាំជាតិ គឺ យក ប្រជាជាតិ ខ្លួនឯង ជា សត្រូវខ្លួន តែម្តង។

[6] ឯកាធភាព=ផ្តាច់មុខ (monopole)។
[7] ហិរិឱត្តប្បៈ=សម្បជញ្ញល្អប្រពៃ (Sagesse)។

## ជនយួន យល់ឃើញ ជនខ្មែរ បែបណា ?

ជនយួន យល់ឃើញ ជា ទូទៅ ថា ជនខ្មែរ ជា មនុស្ស ខ្ជិល មាន ទឹកដី បរិបូរណ៍ មានជីវជាតិ អាចសាបព្រួសបាន តែខ្ជិល មិន រវល់ ធ្វើការយលផល ឲបាន ច្រើនក្រៃលែង។ ដាំស្រូវ តែមួយ ដង ក្នុង មួយ រដូវ បន្ទាប់ មក នាំ គ្នា ធ្វើ បុណ្យ រាំច្រៀង ដេកចាំ រដូវ ថ្មី។

ឧកញ៉ា សុត្តន្តប្រី ជា ឥន្ទ ពន្យល់ អំពី វិបាក កើត មក ពី សេចក្តី ខ្ជិល ថា[8]៖ «...សេចក្តីខ្ជិល នោះមាន នៅហើយ វិជ្ជាទាំងពួង ក៏ពុំអាច មាន ដល់ មនុស្ស ឡើយ បើ ចំណេះវិជ្ជា មិនមាន ហើយ ទ្រព្យសម្បត្តិ នឹងកើត មាន មក អំពី ទីណា ដូចម្តេចបាន កាលបើ ទ្រព្យសម្បត្តិ មិន មានហើយ ធ្វើម្តេចឡើយ នឹងមានមិត្រសំឡាញ់ គេរាប់អាន គឺថា ពុំមាន បុគ្គលឯណាមួយនឹង ចូលមក ជាមិត្រ ជា ភ័ក្តិ ជា ពួងឡើយ កាលបើ មិនមាន មិត្រភ្នាហើយ សេចក្តីសុខ សប្បាយ ឯណា ក៏មាន និង មានតែ សេចក្តីទុក្ខលំបាក ជា ប្រក្រតី...»។ ជនយួន និយាយ បែប **ពាក្យប្រៀប**[9] នឹងខ្ជិល ថា៖ «ពេល យួន ស្ទូង ស្រូវ ខ្មែរ នាំគ្នា ឈរមើល ហើយ លាវ នាំគ្នាដេក ច្រៀងសប្បាយ»។ ពាក្យនេះត្រូវបាន អាជ្ញាធរ អាណានិគម បារាំង នៅ ឥណ្ឌូចិន យកមក ធ្វើ ជា គោលការណ៍ សំរាប់ដឹកនាំ ប្រជាជន ដូចយ៉ាង ទុក យួន ជា នាយ ទុក ខ្មែរនិង លាវជា ពល កម្លាំង។ ជនយួន តែងតែ ទុក វប្បធម៌ ជាតិសាសន៏យួន ថា មាន កំពស់ លើស វប្បធម៌ នៃ ប ណ្តាជន ដ៏ទៃទៀត នៅ ឥណ្ឌូចិន។

## សង្ខេប អំពី ធាតុ ឥណ្ឌូចិន

គួរ បើកវង់ក្រចក ដើម្បី អធិប្បាយ ជា សង្ខេប នូវ អារ្យធម៌ នៅ ឥណ្ឌូចិន។ ឈ្មោះ «ឥណ្ឌូចិន» នេះ គឺ លោក Malte-Brun, អ្នកភូមិសាស្ត្រ មានសញ្ជាតិ ជា ដាណឺរ (Danois) ជា អ្នកដាក់ឈ្មោះ ឲ។ តាមប្រវត្តិសាស្ត្រ ដំបន់ ឥណ្ឌូចិន ជា ផ្លូវឆ្លង សព្វអម្បូរមនុស្ស ជា និច្ចកាល នៅក្នុង សម័យ បុព្វប្រវត្តិសាស្ត្រ ហើយ ទុកស្នាម នូវ វត្តមាន របស់ខ្លួន ដូច ពួក អម្បូរ អូស្ត្រាលី, មាឡាណេ ស៊ី (ជា អម្បូរ គីរីជន សព្វថ្ងៃនេះ), ម៉ុងហ្គោលី (ដែលចេញពីអម្បូរចិន)។ នៅក្នុង សម័យ ប្រវត្តិ សាស្ត្រ មានចលនា ទេសន្តរប្រវេសន៏ មនុស្ស ធំ ៤ មក រស់នៅ នៅ ក្នុង ដំបន់នេះ៖ ទី ១ មក ពី ប្រទេសចិនក្រោមសញ្ញា កម្លាំងទ័ព ឬ ហឹង្សា, ទី២ ពីប្រទេស ឥណ្ឌា ក្រោម សញ្ញា អហឹង្សា។ ឯចំណែកចលនា ធំពីរ ទៀត ចូល តាមផ្លូវ សមុទ្រ គឺ ពួកអ្នកកាន់ សាសនា អ៊ិស្លា ម មក រស់នៅ ក្នុងឧបទ្វីប មាលេ និង ជនជាតិ អឺរ៉ុប (អង់គ្លេស/បារាំងសែស) ចូលមក កាន់ កាប់ ដំបន់ ទាំងមូល តាម កម្លាំងទ័ព នៅក្នុង សតវត្ស ទី១៩។ ការកាន់កាប់ នេះ ត្រូវ រលាយ បាត់អស់ ទៅវិញ ជាមួយនឹង ការរលាយ នៃ អាណានិគម។ គេដឹង ថា ឥណ្ឌូចិន ជា ដំបន់ បិត

[8] សរសេរ នៅក្នុង គតិលោក។
[9] ពាក្យប្រៀប= ពាក្យប្រើប្រដូច (métaphore)។

នៅ រវាង មហានគរពីរ គឺ ចិន និង ឥណ្ឌា ដែល អាច ពន្យល់បាន ងាយ អំពី ឥទ្ធិពល អារ្យធម៌ មហានគរ នេះ មកលើ ប្រជាជន ឥណ្ឌូចិន។

## ១. អារ្យធម៌ ចិន

អារ្យធម៌ ចិន ជ្រួតជ្រាប ចូលមក ក្នុង ឧបដំបន់ តុងកឹង អស់ រយៈពេល ១០ សតវត្ស តាម កម្លាំងទ័ព។ ជា ការច្បាំងដណ្តើម ពីសំណាក់ ចិន កណ្តាល យក ឧបដំបន់ ចិន ខាងត្បូង ធ្វើ ជាអាណាគម ខ្លួន ហើយ នាំមក ជា មួយ កងទ័ព ឈ្លានពាន នូវ របៀប រដ្ឋបាល និង ជំនឿ សាសនា (លទ្ធិ ខុងជីនិយម, លទ្ធិតាវ និង ពុទ្ធសាសនា)។ **សញ្ជ័យ**[10] នេះ នាំ ឲ ជនជាតិ យួន រត់ មក រស់នៅ ក្នុង ឧបដំបន់ តុងកឹង បង្កើតបាន ឧបអារ្យធម៌ យួន រួច ហូរ ធ្លាក់ ទៅទិសខាង ត្បូង ជនលិច ប្រទេស ចំប៉ា និង កម្ពុជាក្រោម។ ប្រទេស វៀតណាម ជា **ប្រតិរូប**[11] ក្នុង ខ្នាត តូចមួយ នៃ អាណាចក្រ ចិន តែ ប៉ុណ្ណោះ ព្រោះ ជាតិសាន៏ យួន ជា ជាតិសាសន៏ មាន ដើម ជា ចិន រស់ នៅ ចិន ខាងត្បូង ជា បងប្អូន រួម លោហិត ហើយ បច្ចុប្បន្ន នេះ ជា មិត្ត រួម លទ្ធិ ផងដែរ ដូច្នេះ យួន មាន កម្លាំង និង ល្បិច ជា ចិន នោះឯង។

## ២. អារ្យធម៌ ឥណ្ឌា

ឥទ្ធពល អារ្យធម៌ ឥណ្ឌា ហូរចូល មកក្នុង ដំបន់ ឥណ្ឌូចិន តាម ផ្លូវជំនួញ នាំ បង្កើត ឲមាន ផែ ចំណត និង ការិយាល័យ ជំនួញ សំរាប់ ទិញ លក់ ដូរ សព្វទំនិញ គ្រប់បែបយ៉ាង ដែលតម្រូវ ឲ ឈ្មួញ មាន ទំនាក់ទំនង ជា មិត្រភាព ជាមួយ នឹង ពួក មេកន្ទ្រាញ ក្នុងដំបន់ នេះ។ លុះ ចំណេរមក មាន មេកន្ទ្រាញ អាចមាន លទ្ធិភាព បោយយកប្រយោជន៏ អំពី ការទំនាក់ ទំនង សេដ្ឋកិច្ច, បច្ចេកទេស សម័យ និង វប្បធម៌ ថ្មី នេះ នាំខ្លួន ឲក្លាយ ជា មហា មេកន្ទ្រាញ ត្រួតលើ មេកន្ទ្រាញ ដទៃទៀត នាំ បង្កើតបាន ជា រាជាណាចក្រ ដែលមាន លទ្ធិហិណ្ឌូ ជា គោល ជំនឿ សាសនា និង របប ដឹកនាំ នគរ។ រាជាណាចក្រ ដែលមានកើតឡើង នោះ គឺ៖ **ចំប៉ា** ស្ថិត នៅ តាមឆ្នេសមុទ្រ យួន កណ្តាល សព្វថ្ងៃនេះ ; អាណាចក្រ **មន** ស្ថិននៅ **អច្ចន្តភាគ**[12] បស្ចិម នៃ ដំបន់ អាស៊ី ភាគ អគ្នេយ៏ ; អាណាចក្រ **ហ្វូណន** ស្ថិតនៅ លើ ដែនដីសណ្តរ នៃ ទន្លេមេកុង អាណាចក្រ នេះ ត្រូវបាន អាណាច្រ ចេនឡា វាយរំលាយ បញ្ជូលក្នុង អាណាចក្រ ខ្លួន ហើយ បង្កើត បន្តបាន ជា ចក្រភព នៅក្នុង សតវត្ស ទី៩ ដែល ជា ចក្រភព មួយ ប្រកបដោយ អំណាច នៅក្នុង តំបន់ អាស៊ុី អគ្នេយ៏។

រវាង សតវត្ស ទី១១ - ទី ១៤ មាន ឃើញមាន ជាតិសាសន៏ ភូមា និង ថៃ ដែល ជា ប្រពលរដ្ឋ សេរី ចាប់ផ្តើម មាន សកម្មភាព ជា កម្លាំង រៀបចំ ធ្វើ ចម្បាំង នឹង អាណាចក្រ មន និង ខ្មែរ ដើម្បី បង្កើត អាណាចក្រ ឯករាជ្យ គឺ អាណាចក្រ ភូមា និង ថៃ។ បន្តមក ក្លាយ ជា នគរ មាន មហិទ្ធានុភាព ក្នុង ដំបន់ ជា ការ នាំឲ អាណាចក្រ ខ្មែរ និង មន អន់ភាព រហូត ក្លាយ ជា

[10] សញ្ជ័យ=ការច្បាំងដណ្តើម (conquête)។
[11] ប្រតិរូប= ឆ្លាក់ពុម្ព (reproduction)។
[12] អច្ចន្តភាគ=ចុងបុះផុត (extrémité)។

ប្រទេស ចំណុះ ប្រទេស ផុសឡើង ថ្មី ទាំង ពីរ ក្រោយ នេះ គឺថា ខ្មែរ ចំណុះ សៀម ឯចំណែក មន ចំណុះ ភូមា។

## ៣. វប្បធម៌ អឺរ៉ុប

មកដល់ សតវត្ស ទី១៩ និង ពាក់ កណ្ដាល ទី២០ ជនជាតិ អឺរ៉ុប បានមក កាន់កាប់ដំបន់ឥណ្ឌូចិន។ ក្នុង រយៈពេលនោះ ដំបន់ អាស៊ី អគ្នេយ៍ ក្លាយ ជា ទឹកដី អាណានិគម នៃ ប្រទេស បស្ចឹម មាន បារាំង និង អង់គ្លេស ជា ប្រទេស អាណានិគម។ បារាំង ត្រួតត្រា ដំបន់ ខាងកើត ឯអង់គ្លេស វិញ ត្រួតត្រា ដំបន់ ខាងលិច។ ចក្រពត្តិនិយម ទាំងពីរ នេះ ស្រុះស្រួល នឹងគ្នា ក្នុងឆ្នាំ ១៨៩៦ទុក ប្រទេស សៀម ឲនៅ ជា ប្រទេស ឯករាជ្យ ដើម្បី ទុកសម្រាប់ធ្វើ ជា **ដំបន់ ទ្រា**[13]។ អាណានិគមអឺរ៉ុប នេះ នាំយក វប្បធម៌ សម័យ មកក្នុង ឥណ្ឌូចិន មាន វិស័យ វិជ្ជាវិទ្យាសាស្ត្រ អក្សរសាស្ត្រវិធី រដ្ឋបាល សម័យ និង របប ដឹកនាំ ជាតិ ដែលនាំ បង្កើត ក្រុម វរជន ថ្មី មួយ ជំនួស វណ្ណៈ មន្ត្រី បុរាណ ឬ នាម៉ឺន។

## ៤. ការទង្គិចគ្នា[14] នៃ ភាពទំនើប នៅ ឥណ្ឌូចិន

### ក. នៅស្រុកខ្មែរ

ក្រោយ សង្គ្រាមលោក លើកទី២ ប្រទេសខ្មែរ ចាប់ពី ឆ្នាំ ១៩៤៧ បើក ទំព័រ ប្រវត្តិសាស្ត្រ ថ្មីមួយ គឺ ការជ្រើសរើស របប ដឹកនាំជាតិ ថ្មី ដោយយក លទ្ធិប្រជាធិបតេយ្យ សេរី ជា គ្រឹះ របប ដែលជា ការបញ្ជាក់ ឲឃើញ ថា ប្រជាជន ខ្មែរ មាន **បក្កភាព**[15] អាចសម្រេច ជ្រើសរើស ជោគវាសនា របស់ ខ្លួន ដោយ ខ្លួនឯង។ ការចេញដំណើរ តាម **មហាមគ្គ**[16] នេះ ជា វឌ្ឍនភាព **ល្ហសលុប**[17] ហើយ ក៏ជា **ច្យុតិ**[18] របស់ ប្រជាជាតិខ្មែរ ដែរ តែ អ្នកនយោបាយ និង អ្នកដឹកនាំជាតិ ខ្មែរ មិនចេះឆក់ យក ភ័ព្វ នេះ មកធ្វើ ជា **ជោគ**[19] សំរាប់ កសាង ប្រជាជាតិ។ ភ័ព្វ មួយទៀត មាន នៅក្នុង ឆ្នាំ ១៩៧០, កើតចេញ ពី ទឹកចិត្ត អ្នកជាតិនិយម មាន យុវជន ជា កម្លាំង ថាមពល នាំគ្នា ទាមទារ ឲ យួន កុម្មុយនិស្ត ចេញ ពី ទឹកដី ខ្មែរ តែ បែ ជា ស្ដេច សីហនុ គាំទ្រ ខ្មាំងជាតិ និង អនុញ្ញាតឲ វា វាយ ទ័ពខ្មែរ បង្កើត ជា សង្គ្រាម ដែលនាំឲ វិនាស ប្រជាជាតិខ្មែរ។ ភាពចង្រៃ មាន បន្តទៀត គឺ ការច្រានចោល ផែនការ សន្តិភាព ឆ្នាំ១៩៧៣ ពី សំណាក់ ពួក ខ្មែរក្រហម ដែលនាំឲ ការរួបរួមជាតិ មិនសម្រេចបាន នៅចំពោះ ហានិភ័យ យួន ព្រោះពួកខ្មែរក្រហម យល់ឃើញ ថា នៅពេលណា ខ្លួន មាន ជ័យជំនះ លើ របប សាធារណរដ្ឋខ្មែរ គឺជាចម្លើយ នៃ បញ្ហា ខ្មែរ និង វៀតណាម។ កម្ម របស់ ខ្មែរ នៅមាន បន្ត មកដល់ ក្នុង ឆ្នាំ ១៩៩៣ គឺ ការបំផ្លាញ ផែនការ សន្តិភាព ២៣ តុលា ឆ្នាំ១៩៩១ ដោយ ឲ លទ្ធិភាព គណបក្សប្រជាជន

[13] ដំបន់ ទ្រា= ដំបន់ ទ្រនាប់ (zone tampon)។
[14] ការទង្គិចគ្នា= Impact។
[15] បក្កភាព= Maturité។
[16] មហាមគ្គ=ផ្លូវធំ (Grande voie)។
[17] ល្ហសលុប=មិនអាចដាកើតម្លៃឲបាន (Inestimable)។
[18] ច្យុតិ=កើតជាថ្មី (Renaissance)។
[19] ជោគ= Atout។

ដែល ជា គណបក្ស រណប យួន អាចរក្សា អំណាច បាន ដើម្បី បំរើ មហិច្ឆិតា វាតទីកដី របស់ វៀតណាម មកក្នុង ស្រុកខ្មែរ។ មហាចង្រៃ មាន មានៈ បន្ត គឺ ការសម្របសម្រួល រវាង គណបក្សប្រជាជន ជាមួយ សង្គ្រោះជាតិ ក្នុងឆ្នាំ ២០១៣ ដែលជាអារុជ ស័ក្តិសិទ្ធិ សំរាប់ សម្លាប់ លទ្ធិប្រជាធិបតេយ្យ សេរី ដើម្បីឲ យួន បន្ត ធ្វើ នយោបាយ បញ្ចូល បន្ថែម ជនជាតិគេ រាប់លាន នាក់ ទៀត មករស់នៅ ក្នុងស្រុកខ្មែរ។ សព្វថ្ងៃនេះ ជនជាតិ យួន រស់នៅ ក្នុង ស្រុកខ្មែរ មិនត្រឹមតែ សង្កត់ ខ្មែរ បាន ដោយសារ មាន ចំនួន ច្រើន តែប៉ុណ្ណោះទេ គឺ គេ សង្កត់ ខ្មែរ បានថែមទៀត ក្នុង ផ្នែក វប្បធម៌ និង ការរស់នៅជាប្រក្រតី ដែល បណ្តាលឲ អ្នកដឹកនាំខ្មែរ ដែលយួន ជា អ្នកបន្ទប កើត ជម្ងឺ ឆ្កួតយួន គឺ ឆ្កួន ស្រី ស្រា និង ល្បែងពាលា ឬ ជាមនុស្ស ប្រព្រឹត្តអំពើទុច្ចរិត បី ប្រការ គឺ កាយទុច្ចរិត វចីទុច្ចរិត និង មនោទុច្ចរិត។ រួមសេចក្តីមក យើងអាចសន្និដ្ឋាន បាន ថា ការទង្គិចគ្នា នៃ ភាពទំនើប មកក្នុង ស្រុកខ្មែរ ជា ការទង្គិចគ្នា ជាអវិជ្ជមាន ព្រោះ ដោយសារ ខ្មែរយើង ឥតខំ កែទម្រង់ មានសិកភាព ដើម្បី ទទួលយកភាពទំនើប ដែលយើង បានជួបប្រទះ មកធ្វើ ជា ថាមពល សំរាប់ កសាង សង្គម និង រដ្ឋសម័យ ដើម្បី សុភមង្គល នៃ ប្រជាពលរដ្ឋ។

## ខ. នៅស្រុកយួន

នៅ ប្រទេស វៀតណាម ក្រោយ សង្គ្រាម លើកទី២ មាន កើត វិបត្តិ នយោបាយ ផ្ទៃក្នុង នាំបង្កើត សង្គ្រាម ស៊ីវិល ផង និង សង្គ្រាម រំដោះជាតិ ពី អាណានិគម បារាំង ផង។ បើ លើកយកស្ថានភាព នេះ មក ប្រៀបធៀប នឹង ខ្មែរ យើង ឃើញ ថា ប្រទេស វៀតណាម មាន ការខកនូវ ការចេញដំណើរ តាម មហាមគ្គ សម័យ ហើយ ដើរ តាម ផ្លូវ សង្គ្រាម អស់ រយៈពេល ច្រើនទស្សវត្តន៍ តែ អ្នកនយោបាយ និង អ្នកដឹកនាំជាតិ យួន គេ ចេះ ធ្វើ រូបបរិវត្ត ស្ថានភាព ដ៍ អភ័ព្វ នេះ ឲក្លាយ ទៅជា ជោគ សំរាប់ ចាក់ ឫស ការតស៊ូប្រជាជន ដែល ជា កត្តា សំរាប់ **ឯកសមោធាន**[20] ទឹកដី និង មោទនភាព ជាតិ។ កត្តា ទាំងពីរ នេះហើយ ដែល អ្នកដឹកនាំជាតិយួន សព្វថ្ងៃ គេ យក មកប្រើ សំរាប់ ឈ្លានពាន ប្រទេស ខ្មែរ និង លាវ។ ហើយ នយោបាយ ចក្រពត្រនិយម នេះ បានទទួល ការគាំទ្រ តាមផ្លូវ ចិត្ត គ្រប់ និន្នាការ នយោបាយ នៃ ប្រជាជនយួន ទាំង ក្រៅ និង នៅក្នុង ប្រទេស។ ខ្មែរ ជា ច្រើន ជា ពិសេស នៅក្នុងចំណោម អ្នចេះដឹងឃើញ យួន ស្រុះស្រួលគ្នា កើត កំហល់ ខឹងនឹង យួន មិននាំ គិតផ្សេង ថា នេះឯងហើយ ជា មេរៀន សំរាប់ ជាតិខ្មែរ ថា ជាតិសាសន៍ យួន គេ ទុក ប្រយោជន៍ ជាតិ គេ មុន ប្រយោជន៍ ក្រុម និង បុគ្គល ដែលខុស ពី ខ្មែរ ភាគច្រើន ទុក ប្រយោជន៍ អញ ជា ដ្ឋាន ចរិត។

អ្នកដឹកនាំជាតិ យួន គ្រប់ជំនាន់ មើលងាយ អ្នកដឹកនាំជាតិ ខ្មែរ ទុកខ្មែរ ជា ជន**វិបល្លាស** (ឆ្កួត) ចាញ់តែបោក ខ្លួន ជានិច្ច ព្រោះ មាន គតិពាល និយមតែ ល្បែង ស្រី ស្រា ដែលគេ ទុកជា ឆ្កួត បីយ៉ាង។ បើ យួន គេ ចង់ សម្លាប់ ខ្មែរ គេ មិនបាច់ ហត់នឿយ យក កម្លាំង គេ ទៅ សម្លាប់នោះឡើយ គេគ្រាន់ តែដើររក ខ្មែរ ណា មាន ត្រីឆ្កួត ក្នុង គតិ មក បំពាក់ យស

[20] ឯកសមោធាន=ការប្រមូលរួបរួមឲមានតែមួយ (Unification)។

ស័ក្តិ ជា ថី ជា នាម៉ឺន ឲប្រកប **មិច្ឆាជិវ:**[21] ឲបាន មាន លុយកាក់ ច្បាស់ ជា ខ្មែរ បែបនេះ មិន ញញើតសម្លាប់ ខ្មែរ គ្នាឯង ដើម្បី សំដែង អំណរគុណ ដល់យួន អស់មួយ ជីវិត។ ទង្វើនេះវា ក្លាយ ជា វប្បធម៌ របបដឹកនាំខ្មែរ ច្រើន ជាយូរយារមកហើយ, លុះចំណេរមក អ្នកដឹកនាំជាតិខ្មែរ យក រាស្ត្រខ្មែរ ជា អាថ៌សត្រូវ របស់ខ្លួន ពួនរស់ ជា សេដ្ឋី ជា **អ្នកអាន់ជ្រី**[22] ក្នុង អនុជអំណាច របស់បរទេស ដែល ជា អ្នកការពារ ខ្លួន ដើម្បី ឲ ខ្លួន មាន លទ្ធភាព សម្លាប់ ខ្មែរ គ្នាឯង ដោយ **អនុបចារ**[23] ដូចយ៉ាង អ្នកដឹកនាំជាតិ សព្វថ្ងៃ ជា **អនុករ**[24] ខ្មែរក្រហម និង ជាដៃយួន តែ ប៉ុណ្ណោះ គឺ នាំគ្នាសម្លាប់ អ្នកស្នេហាជាតិខ្មែរ ឲ ជាតិ ខ្សោយ ដើម្បី ឲ យួន ងាយ លេបស្រុក ខ្មែរ ទាំងមូល។ ក្នុងចំណុច នេះហើយ ដែលនាំឲ អ្នកដឹកនាំយួន គេ មើលងាយខ្មែរ ! តើវា ជា កំហុស យួន ឬ ជាកំហុសខ្មែរ ?

យើង បិទ វង់ក្រចក ហើយ បន្ត ពិនិត្យ អំពី កម្លាំងយួន ដូច ខាងក្រោម នេះ។

## គណបក្ស ប្រឆាំង

គណបក្ស ប្រឆាំង គ្មាន «វប្បធម៌ ប្រឆាំង» គ្មាន «បន្ទាត់ នយោបាយ» ពិតប្រាកដ សំរាប់ ប្រឈរទល់មុខ នឹង នយោបាយ យួន ដែលមាន រៀបចំកម្មវិធិច្បាស់លាស់ សំរាប់ សមិទ្ធិ សុបិន របស់ បក្សកុម្មុយនិស្តយួន គឺ ការរំលាយ ស្រុកខ្មែរ និង លាវ ចូលក្នុង «មហា វៀតណាម» ឬ ឥណ្ឌូចិន ថ្មី។ សព្វថ្ងៃ បក្សកុម្មុយនិស្ត យួន គេ ឥតចាំបាច់ ប្រើ គោលការណ៍ នៃ ការសម្ងាត់ នៅក្នុង វិធាន គេនោះឡើយ ព្រោះ គណបក្ស ប្រឆាំង ជា អង្គការ **អប្បៀសក្ខ**[25] អាចមាន ប្រតិកម្ម ជា កម្លាំង តបត នឹងវិធាន របស់ គេ ដូច្នេះ បក្សកុម្មុយនិស្តយួន គេ មាន វិធាន បើកចំហរ លេបយក ស្រុកខ្មែរ ទាំងស្រស់ ដែល ខ្មែរយើង ឃើញច្បាស់ នូវ សព្វគោលការណ៍មាន នៅក្នុង វិធាន នោះ គឺ៖ គោលការណ៍ «ឪកាស», «ការប្រែប្រួល», «ស្ថានភាព» និង «វិបត្តិ»។

- គោលការណ៍ «ឪកាស», យក ការបោះឆ្នោត «មានតែឈ្មោះ» បោក គណបក្ស ប្រឆាំង ឲ ចូល រួម ការបោះឆ្នោតព្រោះ ដឹងច្បាស់ អំពី ចរិត អ្នកដឹកនាំ ថា បើ គាត់ ទទួលបាន អាសនៈ ចំនួន ច្រើន តិចតួចក្តី គឺគាត់នាំគ្នា យល់ព្រម គោរព លទ្ធផល បោះឆ្នោត ព្រោះ ជា ឆ្នាំង បាយ របស់ ពួកគាត់។

- គោលការណ៍ «ការប្រែប្រួល», យក វិធាន ហឹង្សា ចេញមុខ ដើម្បី បង្ក្រាប ម្ចាស់ឆ្នោត ដែល មិន សុខចិត្ត ទទួល ស្គាល់ លទ្ធផល នៃ ការបោះឆ្នោត ហើយ ធ្វើការសម្លុតដល់ អ្នកដឹកនាំ នៅ

[21] មច្ឆាជិវ:= ការប្រកប ការរសុី ខុសគន្លងធម៌។ ពាក្យផ្ទុយ គឺ សម្មាជីវ:។
[22] អ្នកអាន់ជ្រី= អ្នកលេងកាប់ចាក់។
[23] អនុបចារ=គ្មានកំរិត (sans limite)។
[24] អនុករ= អ្នកធ្វើឲដូច (Imitateur)។
[25] អប្បៀសក្ខ=ហេវកម្លាំង (impuissance)។

ចចេស របស់ គណបក្ស ប្រឆាំង ឲ ឈប់គាំទ្រ ចលនា មហាជន ប្រឆាំងនឹង រដ្ឋាភិបាល អាយ៉ង ដែលខ្លួន បន្តុប សំរាប់ សម្លាប់ខ្មែរ។

- គោលការណ៍ «ស្លានការ», យក ខ្មែរ និង ខ្មែរ ឲក្លាយ ជា សត្រូវនឹងគ្នា មួយ ជា អ្នកស្នេហាជាតិ មួយទៀត ជា អ្នកកាលាននុវត្តនិយម ដើម្បី បំបែក កម្លាំងខ្មែរ ក្នុង គោលបំណង តែមួយគត់ គឺ រក្សា អំណាច អាយ៉ង របស់ខ្លួន។

- គោលការណ៍ «វិបត្តិ», ឆ្លៀត យក វិបត្ត នយោបាយខ្មែរ ដែល ខ្លួន ជា អ្នកបង្កើត ឲមានដើម្បី ឲពួក អាយ៉ង ខ្លួន កាន់តែត្រូវការ កម្លាំង យួន ជា ការចាំបាច់ សំរាប់ បន្តរស់ បម្រើ យួន ក្នុងនាម ជា អ្នកអាន់ជ្រី លើ ខ្មែរ គ្នាឯង។

អ្នកដឹកនាំ គណបក្ស ប្រឆាំង មិនមែន ឥតមាន ភ្នែក មើល ឃើញ គោលការណ៍ របស់យួន ដែលបាន រៀបរាប់ ខាងលើ ហ្នេះឡើយ តែ លោភោ យសសក័ក្តិ លុយកាក់ និង ឆ្អួតយួនរបស់ពួកគាត់ នាំគ្នា ចូលបំរើ នយោបាយ យួន ទាំងស្រុង ក្នុងនាម ជា ជនក្បត់ជាតិ។

## វរជន ថ្មី និង បេសកកម្ម យួនកម្ពុជា

អធិប្បាយ អំពី **វរជន**[26] នៅ ស្រុកខ្មែរៈ សព្វវិស័យ ព្រមទាំង វិស័យ កីឡា សុទ្ធ ជា យួនកម្ពុជា តែគេនិយាយ អួតអាង ថា គេ ជា អ្នករក កិត្តយស ឲខ្មែរ ព្រោះ គេ ធ្វើ ក្នុងនាម ប្រជាជាតិខ្មែរ។ ទស្សនៈ នេះ ល្អ ណាស់ បង្ហាញ ឲឃើញ នូវ ជោគជ័យ នយោបាយ **បូរណកម្ម**[27] ជាតិសាសន៍ នៅស្រុកខ្មែរ តែតាម ការពិត នៅក្នុង សុភនិច្ច័យ បែបនេះ មាន ឧបាយកល ពី អ្នកដឹកនាំយួនឈ្លានពាន ស្រុកខ្មែរ ដោយ យក ជនជាតិយួន ជា កម្លាំង ទឹកហូរ មាន ធារទឹក ខ្លាំងក្លា ហូរចូលមក ក្នុងស្រុកខ្មែរ ដូច បាក់ ទំនប់ទឹក នោះឯង។ បូរណកម្ម ជាតិសាសន៍ នៅក្នុង ស្រុកខ្មែរ ជា នយោបាយ **សមានកម្ម**[28] ជាតិសាសន៍ ខ្មែរ ជា ម្ចាស់ស្រុក ឲក្លាយ ជា អនុប្រជាជន នៃជាតិសាសន៍ យួន ដែល ជា ប្រជាជនអន្តោប្រវេស មក រស់នៅ ក្នុង ទឹកដីខ្មែរ។ សមនកម្ម បែបនេះ គឺ អ្នកដឹកនាំ យួន គេ ធ្វើ ឲ ខ្មែរ នៅ ជាខ្មែរ ក្នុង វប្បធម៌ ហីនភាព តែត្រូវ ចេះ គោរព វប្បធម៌ ជាតិសាសន៍ យួនព្រោះ ជា ជាតិសាន៍ ជា «**មេ**» ឬ «**អ្នកនាំ**» បណ្តា ជាតិសាសន៍ ដទៃទៀត រស់នៅ ក្នុង តណ្ឌូចិនដែល មាន យួន ជា អ្នកគ្រប់គ្រង។ អភិក្រម នៃ សមនកម្ម មាន បីដំណាក់ ថ្មី បន្ទាប់ ពីបានសមិទ្ធិ រួចស្រេច និង ឥតខ្ចោះ នូវ អំណាច នយោបាយ យោធា និងនគរបាល ៖ ទី១ បង្កើត ក្រុម វរជន ថ្មី ដែលមាន ចំនួន ច្រើន ជា យួនកម្ពុជា ដើម្បី គ្រប់គ្រងភូមិ បញ្ញា និង វប្បធម៌ ; ទី២ បញ្ជូល ជនជាតិ យួន មាន ចំនួនដុល រាប់លាន នាក់ ដើម្បី វាតនិង ពង្រីងដំបន់ សេដ្ឋកិច្ច ថ្មី នៅ គ្រប់ ក្រុង តូចធំ និង ដំបន់ ដែលមាន ដី អាចធ្វើ កសិកម្ម បាន។ ជនជាតិយួន ដែល ចូលមក រស់នៅ ក្នុង ស្រុកខ្មែរ មាន តួនាទីជា អ្នក

[26] វរជន=Elite។
[27] បូរណកម្ម=បញ្ជូលឲក្លាយតែមួយ (intégration)
[28] សមានកម្ម=ការធ្វើឲជ្រួតជ្រាប (assimilation)។

ត្រួតត្រាយ នយោបាយ សេដ្ឋកិច្ច និង វប្បធម៌ ដូច្នេះ គេបំពាក់ គំនិត ជឿ ថា ទឹកដី កម្ពុជា ជា ទឹកដី ដែល ម៉េឪ គេ វាយ ដណ្ដើម បាន ពី ខ្មែរ ដើម្បី ទុក ជា មរតក ដល់ កូនចៅយួន ដូច្នេះ គេ មាន កាតព្វកិច្ច ធ្វើអាជីវកម្ម បង្កើត ផល និង ថែរក្សា ឲបាន គង់វង់ សំរាប់ កូនចៅយួន បន្តគ្នា ទៅមុខទៀត។ ទី៣ ជា ដំណាក់ ឈុតបញ្ចប់ គឺ យួន ទុក កម្ពុជា ដូច ជា កម្ពុជាក្រោម មាន អត្ថិភាព តែ ឈ្មោះ តែមាន ជាតិសាសន៍ យួន ជា កម្មសិទ្ធិករ រស់នៅ ជា ឧត្តមប្រជាជន លើ ខ្មែរ ដែល យួន ទុក ជាវណ្ណៈសូទ្រៈ ឬ បាវបំរើ ដែល មាន នៅក្នុងព្រហ្មញ្ញសាសនា និង របប សក្តិភូមិ។

## សេចក្តី សន្និដ្ឋាន

កម្លាំង យួន លើស កម្លាំង ខ្មែរ មកពី ខ្មែរយើង មាន មារយាទ ឲគេ មើលងាយ។ ការមើលងាយ នេះ ជា **ឧបបាតិក**[29] ក្នុង គតិ ជនជាតិយួន មាន មកលើ ខ្មែរ ច្រើន សតវត្ស មកហើយ ព្រោះ ជាតិសាសន៍ យួន គេ តែងតែ មាន ជ័យជំនះ ជា និច្ច មកលើ ជាតិសាសន៍ខ្មែរ។ បើ និយាយ ឲងាយ យល់ គឺ កម្លាំង យួន កើតមកពី កម្លាំង ខ្មែរ ខ្សោយ នោះឯង។ តាំង ពី មាន ជំនួប ខ្មែរ ជាមួយ យួន មក ជាតិសាសន៍ យួន តែងតែ មាន ប្រៀប លើ ជាតិសាសន៍ខ្មែរ ជានិច្ច។ ទង្វើ ស្រំដែលនេះ នាំពង្រឹង ចិត្តគំនិត នៃ ឧត្តមភាព យួនលើ ខ្មែរ ដែល គេ ឲ ឈ្មោះ វា ថា «ការត្រិះរិះ ជា វិជ្ជមាន» លើស ពី នេះ ទៅទៀត វា ក្លាយ ជា «ការត្រិះរិះ ជា សកម្ម» ព្រោះ វា ផ្អែកលើ ការពិត ជាក់ស្តែង គឺ ជ័យជំនះ បន្តៗគ្នា ជា និច្ច របស់យួន រហូត មកដល់ បច្ចុប្បន្នកាល នេះ។

សព្វថ្ងៃ នេះ ខ្មែរភាគច្រើន ហាក់បីដូចជា សុខចិត្ត សុខកាយ រួមរស់ ជា មួយ ជនជាតិយួន នៅ ក្នុង ស្រុកខ្មែរ ព្រោះ យួន ជា ដង្ហើម **សេដ្ឋកិច្ច រស់នៅ ជា ប្រក្រតី**[30] និង របៀប រស់នៅ របស់ ជនជាតិខ្មែរ។ ស្ត្រីខ្មែរ នាំគ្នា ពាក់ខោ ដូច ស្ត្រី យួន នាំគ្នា យល់ឃើញ ថា សារុងខ្មែរ ជា ការ រំខាន ដល់កាយវិការក្នុង ការប្រកប របរ ជិវិៈ ; ជនជាតិខ្មែរ ទាំង ប្រុស ស្រី ជៀស មិនឲមាន អធិករណ៏ ជាមួយ យួន ទោះបី ដឹងថា យួន បំពាន ខ្លួន បែបណា ក៏ដោយ ព្រោះ ដឹងមុន ស្រេច ថា ខ្លួនមិនឈ្នះ យួន ជា ដាច់ខាត ព្រោះ ជនជាតិយួន ក្លាយ ជា ប្រជាជន កម្ពុជា មាន ឋានៈ ខ្ពស់ ជាង ខ្លួន នៅក្នុង ការអនុវត្តន៏ ច្បាប់រដ្ឋ ពី សំណាក់ អាជ្ញាធរ ប៉ូលិស និង តុលាការ ដែល មាន ជនកម្ពុជា មាន ដើម កំណើត ជា យួន ជា អ្នកកាន់កាប់ ក្រសួង។ ក្រសួង ទាំងពីរ នេះ គេ មាន អនុទ្ទេស ក្រសួង ច្បាស់លាស់ ក្នុង ប្រព្រឹត្តច្បាប់ ខុសគ្នា រវាង ប្រជាជនខ្មែរ និង ប្រជាជនកម្ពុជា៖ កំហុស ដែល យួនកម្ពុជា ធ្វើខុស ទៅលើខ្មែរ ត្រូវក្រសួង មាន សេចក្តីអត់ឳន ទុក ជា សគុណ យួន ដែលបាន មកជួយខ្មែរ នៅថ្ងៃ ទី៧ មករា ឆ្នាំ ១៩៧៩, តែ បើ ខ្មែរ ធ្វើ ខុស វិញ ទៅលើ យួនកម្ពុជា ទោះបី ត្រឹម ជា បទល្មើស តែ គេទុកទោសនោះ ជា ទោស ប្រកាន់

---

[29] ឧបបាតិក=កើតមានដោយខ្លួនឯង (né de lui-même)។
[30] សេដ្ឋកិច្ច រស់នៅ ជា ប្រក្រតី= Economie de subsistance។

ពូជសាសន៍ ស្មើនឹង បទឧក្រិដ្ឋ។ យួនកម្ពុជា ជា **អនិគជន**[31] ច្បាប់ខ្មែរ ព្រោះ គេ ជាម្ចាស់ ស្រុកខ្មែរ។ ឧទាហរណ៍ នៅក្នុង គុក ខ្មែរ គ្មានមាន ជនទុច្ចរិត យួនកម្ពុជា សោះឡើយ។

និយាយ រួម មក កម្លាំង យួន នៅក្នុង ស្រុកខ្មែរ មាន ទាំង កម្លាំង ចិត្ត កម្លាំង កាយ កម្លាំង ច្បាប់ កម្លាំង វប្បធម៌។ សួរថា តើ ខ្មែរ យើង នៅមាននៅសល់ កម្លាំង ណាមួយដែរ សម្រាប់ ធ្វើជាអាវុធ តស៊ូប្រឆាំង នឹង អភិក្រម នៃ នយោបាយ លេបទកដីខ្មែរ ដែលបាន រៀបរាប់ ខាងលើ នេះ ដែរ រឺទេ ? ចម្លើយ នេះ យើងនឹង លើកវា យកមក សិក្សា នៅថ្ងៃក្រោយ។

- **ចប់** -

ថ្ងៃទី ១២ ធ្នូ ឆ្នាំ ២០១៤

ឧប សៅ សង្ខា

[31] អនិគជន=ជនរស់នៅក្រៅច្បាប់។